ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សេចក្តីជូនដំណឹង

## ស្តីពី

## ការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យកាត់ដេរ និងទេសចរណ៍ ដែលត្រូវបានព្យួរកិច្ចសន្យាការងារស្របតាមស្មារតីនៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល (លើកទី៤៩)

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់បងប្អូនកម្មករនិយោជិតចំនួន ៦ ០៤០ នាក់ នៃរោងចក្រ សហគ្រាស ទាំង៣៩ នៃវិស័យកាត់ដេរ និងវិស័យទេសចរណ៍ (ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ) ដែលទទួលបានការអនុញ្ញាតព្យួរកិច្ចសន្យាការងារស្របតាមស្មារតីជុំទី៣នៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាលជ្រាបថា ធនាគារឯកទេសវីង នឹងផ្ញើសារអំពីការបើកប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលទៅលេខទូរសព្ទ ដែលបងប្អូនបានផ្តល់មកឱ្យក្រសួងតាមរយៈរដ្ឋបាលរោងចក្រ សហគ្រាសនាពេលកន្លងមក។

ប្រាក់ឧបត្ថម្ភនេះនឹងត្រូវបើកផ្តល់ជាប្រាក់រៀល និងអាស្រ័យលើចំនួនថ្ងៃនៃការព្យួរកិច្ចសន្យាការងារ ក្នុងនោះចំនួនៈ

- ៦០ ៧៥០រៀល (១៥ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ៧ថ្ងៃ ដល់ ១០ថ្ងៃ
- ១២១ ៥០០រៀល (៣០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១១ថ្ងៃ ដល់ ២០ថ្ងៃ
- ១៦២ ០០០រៀល (៤០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេលចាប់ពី ២១ថ្ងៃ ដល់ ១ខែ។ សូមបញ្ជាក់ថា សម្រាប់បងប្អូនដែលព្យួរកិច្ចសន្យាការងាររយៈពេល ២ខែ ប្រាក់ឧបត្ថម្ភនឹងត្រូវបើកជា ២លើក ដោយលើកទី២ នឹងបើកនៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២១។

ក្រសួងសូមរំឭកថា ធនាគារឯកទេសវីង នឹងបង្វិលប្រាក់ឧបត្ថម្ភនេះជូនរាជរដ្ឋាភិបាលវិញ ប្រសិនជាបងប្អូនខកខានមិនបានទៅបើកប្រាក់ឧបត្ថម្ភនេះ ក្នុងរយៈពេល ១០ថ្ងៃ បន្ទាប់ពីទទួលបានសារតាមទូរសព្ទពីធនាគារឯកទេសវីង។ ដើម្បីបើកប្រាក់ឧបត្ថម្ភនេះ បងប្អូនត្រូវយកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងទូរសព្ទដែលទទួលបានសារនោះទៅកាន់ភ្នាក់ងារវីងដែលនៅជិតបំផុត។ សូមបញ្ជាក់ថា បងប្អូនមិនតម្រូវឱ្យបង់ថ្លៃសេវាទៅភ្នាក់ងារវីងឡើយពេលបើកប្រាក់ឧបត្ថម្ភនេះ។

ក្នុងករណីបងប្អូនកម្មករនិយោជិត ដែលបម្រើការងារនៅរោងចក្រ សហគ្រាស ទាំង៣៩ នេះ មិនបានទទួលសារទូរសព្ទពីធនាគារឯកទេសវីង នោះសូមបងប្អូនទំនាក់ទំនងសួរព័ត៌មានបន្ថែម ឬធ្វើបច្ចុប្បន្នភាពលេខទូរសព្ទរបស់ខ្លួន ទៅរដ្ឋបាលរោងចក្រ សហគ្រាសរបស់ខ្លួន។ ក្រសួងនឹងបន្តជូនដំណឹងដល់បងប្អូនកម្មកររោងចក្រ សហគ្រាសដទៃផ្សេងទៀតអំពីការបើកផ្តល់ប្រាក់ឧបត្ថម្ភនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជាពិសេសបងប្អូនកម្មករនិយោជិតជ្រាបជាព័ត៌មាន និងសូមរួសរាន់ទំនាក់ទំនងបើកប្រាក់ឧបត្ថម្ភនេះនៅតាមភ្នាក់ងារវីងនានាដែលនៅជិតបំផុតឱ្យបានទាន់ពេលវេលា។

ថ្ងៃ ព្រហស្បតិ៍ ៧រោច ខែ មាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ៤ ខែ កុម្ភៈ ឆ្នាំ២០២១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**គណៈកម្មការអនុវត្តវិធានការរាជរដ្ឋាភិបាល**

**ឧបសម្ព័ន្ធ នៃសេចក្តីជូនដំណឹងចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២១**

**បញ្ជីឈ្មោះ រោងចក្រ សហគ្រាស ក្នុងវិស័យកាត់ដេរ និងវិស័យទេសចរណ៍**
**ចំនួន ៣៩ ដែលទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល**

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| ក. វិស័យកាត់ដេរ | | 15 |
| 1 | ក្រុមហ៊ុន ថេកអូហ្វ (ខេមបូឌា) | ភ្នំពេញ |
| 2 | ក្រុមហ៊ុន ណាន់ គង់ ហ្គាមេន (ខេមបូឌា) | ភ្នំពេញ |
| 3 | ក្រុមហ៊ុន ឌូហ៊ីស្គ(ខេមបូឌា)ខូអ៊ិលធីឌី | ភ្នំពេញ |
| 4 | ក្រុមហ៊ុន ដាប់ប៊ីលយូ អ៊ែនដ៏ ឌី កម្ពុជា | ភ្នំពេញ |
| 5 | ក្រុមហ៊ុន ឥណ្ឌូចិនអ៊ីភែរឹល (ខេមបូឌា) អិលធីឌី | កណ្ដាល |
| 6 | ក្រុមហ៊ុន ដា រ៉ុង ព្រីនធីង & អ៊ីមប្រយឌើរី | កណ្ដាល |
| 7 | ក្រុមហ៊ុន មូនតៃ ខេជេ (ខេមបូឌា) ខូអិលធីឌី | កណ្ដាល |
| 8 | ក្រុមហ៊ុន ជីនវីន អ៊ីនដាសស្ទ្រី ខេមបូឌា ខូអិលធីឌី | កណ្ដាល |
| 9 | ក្រុមហ៊ុន ញូ ហ្វូខឹស អ៊ីភែរឹល (ខេមបូឌា) ឯ ក | កណ្ដាល |
| 10 | ក្រុមហ៊ុន អ៊ី ហ្គាមេន ខូអិលធីឌី | កណ្ដាល |
| 11 | ក្រុមហ៊ុន អ៊ែដហ្សាយល៍ ស្វេតចឺ(ខេមបូឌា)ខូ អិលធីឌី | កំពង់ស្ពឺ |
| 12 | ក្រុមហ៊ុន ណានវ៉ាង ត្រាវែល ហ្គូដស៍ ឯក | កំពង់ស្ពឺ |
| 13 | ក្រុមហ៊ុន ថបស៊ីលវើរ លីមីធីត (សាខាទី1) | ត្បូងឃ្មុំ |
| 14 | ក្រុមហ៊ុន ជេ អេស ឌី ថេកស្ថាយ (ខេមបូឌា) | តាកែវ |
| 15 | ក្រុមហ៊ុន អរិន មេនូហ្វេកឆឺរីង ( ខ្មែរ ) | ព្រៃវែង |
| ខ. វិស័យទេសចរណ៍ | | 24 |
| 1 | សណ្ឋាគារ ហ្គាឌិន ស៊ីធី ហូថេល | ភ្នំពេញ |

| ល.រ | ឈ្មោះភោជនីយដ្ឋាន សណ្ឋាគារ | រាជធានី ខេត្ត |
|---|---|---|
| 2 | សណ្ឋាគារ រ៉ាហ្វ៊ល រ៉ូយ៉ាល់ | ភ្នំពេញ |
| 3 | សណ្ឋាគារភ្នំពេញ អេរ៉ា ហូថេល ឯ.ក | ភ្នំពេញ |
| 4 | ក្រុមហ៊ុន វើលដ៏ អិចប្រេស | ភ្នំពេញ |
| 5 | ក្រុមហ៊ុន យូ យូ ត្រាវែល អេជេនស៊ី | ភ្នំពេញ |
| 6 | សណ្ឋាគារ លីនាយាអង្គរ រីសត និងស្ប៉ា | សៀមរាប |
| 7 | ក្រុមហ៊ុន កូបេ យៃភែននីស វ៉ស្កូវែន | សៀមរាប |
| 8 | សណ្ឋាគារ សុខាអង្គរ | សៀមរាប |
| 9 | សណ្ឋាគារ អង្គរមិរ៉ាខល រីហ្សត និង ស្ប៉ា | សៀមរាប |
| 10 | ក្រុមហ៊ុន អង្គរ សេនជូរី គ្រុប ភីធីអ៊ី អែលធីឌី | សៀមរាប |
| 11 | សណ្ឋាគារ សាងមសៀមរាប | សៀមរាប |
| 12 | ក្រុមហ៊ុន ខ្មែរអង្គរហូថែលកូអិលធីឌី | សៀមរាប |
| 13 | ក្រុមហ៊ុន គ្រេហ្ស៊ី អូអេស៊ីស | សៀមរាប |
| 14 | ក្រុមហ៊ុន ផ្កាចន្ទន៏ សៀមរាប យ៉ុងឆាង | សៀមរាប |
| 15 | ក្រុមហ៊ុន ដឹសឃ្សែរ24 | សៀមរាប |
| 16 | ក្រុមហ៊ុន អឹបៅអេស៊ា | សៀមរាប |
| 17 | សណ្ឋាគារសុខាល័យអង្គរ រីហ្សត និងស្ប៉ា | សៀមរាប |
| 18 | ក្រុមហ៊ុន រ៉ាហ្វលមហាសណ្ឋាគារអង្គរ | សៀមរាប |
| 19 | ភោជនីយដ្ឋាន នារីខ្មែរ | សៀមរាប |
| 20 | សណ្ឋាគារតាព្រហ្ម | សៀមរាប |
| 21 | ក្រុមហ៊ុន ម៉េម៉រអង្គរ (ខេមបូឌា) | សៀមរាប |
| 22 | សណ្ឋាគារ លីនរតនះអង្គរ | សៀមរាប |
| 23 | សណ្ឋាគារ វីណាហ្គហ្វ អង្គរ | សៀមរាប |
| 24 | ក្រុមហ៊ុន អេពិច ខេមបូឌា ត្រាវ៉ែល ស៊ែវីស | សៀមរាប |